**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**

លេខ: ០០០១ រ៉ែ.បណ.សវណ

ថ្ងៃ ចន្ទ ៨កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងរ៉ែ និងថាមពល សម្រាប់ឆ្នាំ២០២៣

ក្រសួងរ៉ែ និងថាមពល សូមជូនដំណឹងដល់និស្សិត និងសាធារណៈជនជ្រាបថា សម្រាប់ឆ្នាំ២០២៣ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មី (ក្របខ័ណ្ឌ "ក") ចំនួន ១១កន្លែង មានតាមការកំណត់ដូចខាងក្រោម៖

### ១. មុខជំនាញជ្រើសរើស

- សេដ្ឋកិច្ច គណនេយ្យ ហិរញ្ញវត្ថុ
- នីតិសាស្ត្រ រដ្ឋបាលសាធារណៈ

### ២. អង្គភាពជ្រើសរើស

២.១ នៅទីស្តីការក្រសួង ចំនួន ០៦កន្លែង។

២.២ នៅមន្ទីររ៉ែ និងថាមពលរាជធានី/ខេត្ត ចំនួន ៥កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ | អង្គភាពត្រូវការជ្រើសរើស | ចំនួន |
|---|---|---|
| ១ | មន្ទីររ៉ែ និងថាមពលខេត្តតាកែវ | ០១ កន្លែង |
| ២ | មន្ទីររ៉ែ និងថាមពលខេត្តព្រៃវែង | ០១ កន្លែង |
| ៣ | មន្ទីររ៉ែ និងថាមពលខេត្តកោះកុង | ០១ កន្លែង |
| ៤ | មន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ | ០២ កន្លែង |

### ៣. លក្ខខណ្ឌជ្រើសរើស

បេក្ខជនដាក់ពាក្យស្នើសុំប្រឡងប្រជែង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ សម្រាប់អាយុមិនឱ្យលើសពី៣៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ សម្រាប់អាយុមិនឱ្យលើសពី ៤០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្របណ្ឌិត សម្រាប់លក្ខខ័ណ្ឌអាយុត្រូវបានលើកលែង។

## ៤. វិញ្ញាសាប្រឡង

វិញ្ញាសា ប្រឡងមានពីរលើកៈ

**៤.១ លើកទី១ ជាវិញ្ញាសាសរសេរមានៈ**

- វប្បធម៌ទូទៅ (រយៈពេល ១ម៉ោង និង៣០នាទី) មេគុណនឹង១
- ភាសាអង់គ្លេសទូទៅ (រយៈពេល ១ម៉ោង និង៣០នាទី) មេគុណនឹង១
- ជំនាញបច្ចេកទេស (រយៈពេល ៣ម៉ោង) មេគុណនឹង២

**៤.២ លើកទី២ ជាវិញ្ញាសាធ្វើបទបង្ហាញ** លើប្រធានបទ ដែលកំណត់ដោយគណៈកម្មការប្រឡងប្រជែង ចំពោះបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាទី១។

## ៥. កាលបរិច្ឆេទប្រឡង

- វិញ្ញាសាលើកទី១ នឹងប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី០៩ ខែមេសា ឆ្នាំ២០២៣**
- វិញ្ញាសាលើកទី២ ដូចមានក្នុងចំណុច ៤.២ ខាងលើ នឹងមានការជូនដំណឹងបន្ទាប់ពីការជូនដំណឹងលទ្ធផលនៃវិញ្ញាសាលើកទី១។

## ៦. មណ្ឌលប្រឡង

មណ្ឌលប្រឡងសម្រាប់វិញ្ញាសាទាំង២ នឹងមានជូនដំណឹងនាពេលក្រោយ។

## ៧. ទីកន្លែង និងកាលបរិច្ឆេទផ្តល់ពាក្យ ទទួលពាក្យ និងឈប់ទទួលពាក្យ

*៧.១ ទីកន្លែង និងកាលបរិច្ឆេទផ្តល់ពាក្យ និងទទួលពាក្យៈ* ការផ្តល់ និងទទួលពាក្យប្រឡងប្រព្រឹត្តទៅចាប់ពីថ្ងៃជូនដំណឹងនេះតទៅនៅរៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកពីម៉ោង៧:៣០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលពីម៉ោង ១៤:៣០នាទីដល់ម៉ោង១៧:០០នាទីល្ងាច នៅច្រកចេញចូលតែមួយ នៃទីស្តីការក្រសួងរ៉ែ និងថាមពល មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

*៧.២ កាលបរិច្ឆេទឈប់ផ្តល់ពាក្យនិងទទួលពាក្យៈ* ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

## ៨. សំណុំលិខិតដែលបេក្ខជនត្រូវបំពេញ ក្នុងការដាក់ពាក្យប្រឡង

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. ជីវប្រវត្តិរូបសង្ខេបមានបិទរូបថត (៤x៦) | ចំនួន ០១ច្បាប់ |
| ៣. កិច្ចសន្យាការងារ | ចំនួន ០១ច្បាប់ |
| ៤. រូបថតថ្មី (៦ខែចុងក្រោយ) ទំហំ ៤x៦ | ចំនួន ០២សន្លឹក |
| ៥. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០២ច្បាប់ |
| ៦. សលាកបត្រឯកត្តជន | ចំនួន ០២ច្បាប់ |
| ៧. សេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណថតចម្លងមានបញ្ជាក់ផ្លូវការ | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងសញ្ញាបត្រឧត្តមសិក្សា (បញ្ជាក់ផ្លូវការ) | ចំនួន ០២ច្បាប់ |

*សេចក្តីបញ្ជាក់ៈ*

- បេក្ខជនមានពិការភាព និង ជាស្ត្រី ដែលមានសមត្ថភាពសមស្រប នឹងត្រូវបានផ្តល់អាទិភាព

- បេក្ខជនមានពិការភាព ត្រូវមានលិខិតបញ្ជាក់ពិការភាពពីអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច
- ព័ត៌មានលម្អិត សូមមកធ្វើទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិករៀងរាល់ម៉ោងធ្វើការ ឬតាមរយៈ
  លោក **សុទ្ធ សារុំ** ទូរស័ព្ទលេខ*០៩៦ ៦៦០ ៩៩០០/ ០៩៧ ៧២៨ ៤៣១៩*
  លោក **ផាត់ នីរ៉ូត** ទូរស័ព្ទលេខ*០១០ ៧៦៧ ៨៧៦*

អាស្រ័យហេតុនេះ សូមនិស្សិត និងសាធារណៈជន មេត្តាជ្រាបជាព័ត៌មាន។

**រដ្ឋលេខាធិការ**
**និងជាប្រធានគណៈកម្មការប្រឡងប្រជែង**

**ស៊ុយ ឌីម៉ង់**

**កន្លែងទទួលៈ**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលខេត្ត ដែលពាក់ព័ន្ធ
- គ្រប់អង្គភាពចំណុះទីស្តីការក្រសួងរ៉ែ និងថាមពល
- គ្រប់មន្ទីររ៉ែ និងថាមពលរាជធានីខេត្ត
- ឯកសារ កាលប្បវត្តិ